# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៧ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## ការទទួលស្គាល់សាកលវិទ្យាល័យឡានម៉េ កម្ពុជា
## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណៈវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយដែលមានឈ្មោះថា "សាកលវិទ្យាល័យឡានម៉េកម្ពុជា" សរសេរជាអក្សរកាត់ថា "**ស.ឡ.ក**" និងជាភាសាអង់គ្លេសថា "Lanmei University of Cambodia" សរសេរជាអក្សរកាត់ថា "L.U.C" ។

**មាត្រា២.-**

**ស.ឡ.ក** មានទីតាំងស្ថិតនៅអគារ ECC ឬ មជ្ឈមណ្ឌលពាណិជ្ជកម្មយៀកថៃ (ជាន់ទី៣, ៣A, ទី៥, ទី៩ និងទី១០) លេខ២២៧ តាមបណ្តោយមហាវិថីព្រះនរោត្តម(៤១) សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ និងស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៣.-**

**ស.ឡ.ក** បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង និងបរិញ្ញាបត្រ ដែលមានមហាវិទ្យាល័យចំនួន៥ ដូចខាងក្រោម៖

១. មហាវិទ្យាល័យអាកាសចរណ៍ស៊ីវិល **(Faculty of Civil Aviation)**

១.១. ដេប៉ាតឺម៉ង់សេវាកម្មបម្រើតាមយន្តហោះ (Department of Flight Attendant)

- ជំនាញសេវាកម្មបម្រើតាមយន្តហោះ (Flight Attendant)

១.២. ដេប៉ាតឺម៉ង់ជួសជុលនិងថែទាំយន្តហោះ ((Department of Aircraft Maitenance)

- ជំនាញជួសជុលនិងថែទាំយន្តហោះ (Aircraft Maitenance)

១.៣. ដេប៉ាតឺម៉ង់គ្រប់គ្រងសេវាដឹកជញ្ជូនតាមផ្លូវអាកាស (Department of Air Traffic Control)

- ជំនាញគ្រប់គ្រងសេវាដឹកជញ្ជូនតាមផ្លូវអាកាស (Air Traffic Control)

២. មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា **(Faculty of Science and Technology)**

២.១. ដេប៉ាតឺម៉ង់បច្ចេកវិទ្យាព័ត៌មានកុំព្យូទ័រ ( Department of Computer Science)

- ជំនាញបច្ចេកវិទ្យាព័ត៌មានកុំព្យូទ័រ (Computer Science)

២.២. ដេប៉ាតឺម៉ង់បច្ចេកវិទ្យារថយន្ត (Department of Automobile Technology)

- ជំនាញបច្ចេកវិទ្យារថយន្ត (Automobile Technology)

២.៣. ដេប៉ាតឺម៉ង់វិទ្យាសាស្ត្រសត្វ និងវិទ្យាសាស្ត្ររុក្ខជាតិ (Department of Animal Science and Plant Science-Postharves)៖

- ជំនាញវិទ្យាសាស្ត្រសត្វ (Animal Science)
- ជំនាញវិទ្យាសាស្ត្ររុក្ខជាតិ (Plant Science-Postharves)

៣. មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ និងភាសា **(Faculty of Linguistic Science and Arts)**

៣.១. ដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ (Department of Khmer Literature)

- ជំនាញអក្សរសាស្ត្រខ្មែរ (Khmer Literature)

៣.២. ដេប៉ាតឺម៉ង់ភាសាអង់គ្លេស (Department of English Language)

- ជំនាញភាសាអង់គ្លេស (English Language)

៣.៣.ដេប៉ាតឺម៉ង់ភាសាចិន (Departmnet of Chinese Language)

- ជំនាញភាសាចិន (Chinese Language)

៤. មហាវិទ្យាល័យមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម **(Faculty of Humanities and Social Sciences)**

៤.១. ដេប៉ាតឺម៉ង់សេដ្ឋកិច្ចឌីជីថល ( Department of Digital Economy )

- ជំនាញសេដ្ឋកិច្ចឌីជីថល (Digital Economy)

៤.២. ដេប៉ាតឺម៉ង់ទំនាក់ទំនងប្រព័ន្ធផ្សព្វផ្សាយ (Department of Media and Communication)

- ជំនាញប្រព័ន្ធផ្សព្វផ្សាយនិងទំនាក់ទំនង (Media and Communication)

៤.៣. ដេប៉ាតឺម៉ង់ការគ្រប់គ្រងកីឡា (Department of Sport Management)

- ជំនាញការគ្រប់គ្រងកីឡា (Sport Management)

៥. មហាវិទ្យាល័យទេសចរណ៍ និងបដិសណ្ឋារកិច្ច **(Faculty of Tourism and Hospitality)**

៥.១. ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍ ( Department of Tourism Management )

- ជំនាញគ្រប់គ្រងទេសចរណ៍ ( Tourism Management )

៥.២. ដេប៉ាតឺម៉ង់គ្រប់គ្រងបដិសណ្ឋារកិច្ច ( Department of Hotel Management and Hospitality )

- ជំនាញគ្រប់គ្រងសណ្ឋាគារនិងបដិសណ្ឋារកិច្ច ( Hotel Management and Hospitality )

៥.៣. ដេប៉ាតឺម៉ង់ពិពណ៌សេដ្ឋកិច្ច ( Department of Exhibition Economy )

- ជំនាញពិពណ៌សេដ្ឋកិច្ច ( Exhibition Economy )

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្តុះបណ្តាលថ្មី រៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ សុំប្តូរឈ្មោះថ្មី ទីតាំងថ្មី ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤.-**

**ស.ឡ.ឆ** មានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្តែងនៃ **ស.ឡ.ឆ** ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

សាកលវិទ្យាធិការនៃ**ស.ឡ.ឆ** មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រង**ស.ឡ.ឆ** និងធានាឱ្យមានសុវត្ថិភាពនិងសណ្តាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការជ្រើសរើសសិស្ស និស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិនមុននឹងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់អំពីសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា

- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាលជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦.-**

និស្សិតដែលបានរៀនចប់តាមកម្មវិធីសិក្សា និងបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះ ត្រូវផ្តល់ឱ្យដោយ**ស.ឡ.ភ** ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរ ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃ**ស.ឡ.ភ** ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃព្រហស្បតិ៍ ៩ កើត ខែ ភទ្របទ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី២៧ ខែ សីហា ឆ្នាំ២០២០

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលរាជធានីភ្នំពេញ
- ដូចមាត្រា ៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ